**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០២៣ សហវ

# សេចក្តីណែនាំ
## ស្តីពី
## នីតិវិធីនៃការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់

យោងព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំអំពីនីតិវិធីនៃការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់ដូចខាងក្រោម÷

### ១ .គោលការណ៍ទូទៅ

សេចក្តីណែនាំនេះ មានគោលបំណងកំណត់ពីសមត្ថភាពអនុវត្តការងារនិងលក្ខណសម្បត្តិរបស់អ្នកទទួលការសាងសង់ដើម្បីអាចចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ។

សេចក្តីណែនាំនេះ មានគោលដៅកំណត់អំពីលក្ខណៈវិនិច្ឆ័យនិងនីតិវិធីវាយតម្លៃលក្ខណសម្បត្តិរបស់អ្នកទទួលការសាងសង់ដើម្បីចុះបញ្ជីចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកទទួលការសាងសង់។

សេចក្តីណែនាំនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់អ្នកទទួលការសាងសង់ដែលមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្មសារធារណៈនៅគ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម និងអង្គភាពថវិកានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ២. និយមន័យ

និយមន័យនៃបច្ចេកស័ព្ទដែលប្រើនៅក្នុងសេចក្តីណែនាំនេះត្រូវបានកំណត់ន័យដូចតទៅ÷

- **ការធ្វើចំណាត់ប្រភេទនិងចំណាត់ថ្នាក់អ្នកទទួលការសាងសង់** សំដៅដល់ការចុះបញ្ជី និងការបែងចែកតាមប្រភេទអ្នកទទួលការសាងសង់ ដោយអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- **អ្នកទទួលការសាងសង់** សំដៅដល់បុគ្គល ឬជាក្រុមហ៊ុន/សហគ្រាសដែលធ្លាប់បានចុះកិច្ចសន្យាលើការងារសាងសង់និងការងារជួសជុលគម្រោងហេដ្ឋារចនាសម្ព័ន្ធ។
- **គម្រោងហេដ្ឋារចនាសម្ព័ន្ធ** សំដៅដល់ការសាងសង់ ការកែលម្អ ឬការស្តារឡើងវិញនូវអគារ ផ្លូវថ្នល់ ស្ពាន ព្រលានយន្តហោះ ផ្លូវរថភ្លើង កំពង់ផែ ប្រព័ន្ធគ្រប់គ្រងទឹកជំនន់ និងប្រឡាយទឹក ការផ្គត់ផ្គង់ទឹកស្អាតនិងប្រព័ន្ធលូទឹកស្អុយ សំរាម ឬកាកសំណល់ ប្រព័ន្ធធារាសាស្ត្រ ទំនប់ទឹក សំណង់ទូរគមនាគមន៍ ការជីកដី ឬចាក់បំពេញ រោងចក្រផលិតអគ្គិសនី ទំនប់វារីអគ្គិសនី និងគម្រោងសំណង់ផ្សេងៗទៀត។
- **ចំណាត់ថ្នាក់** សំដៅដល់ការចាត់ចូលជំនាញក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ ស្ពាន ព្រលានយន្តហោះ សំណង់អគារ ជាដើម។
- **ចំណាត់ប្រភេទ** សំដៅដល់ការកំណត់លក្ខណសម្បត្តិរបស់អ្នកទទួលការសាងសង់កម្រិត តូច មធ្យម និងធំ។
- **គ្រឿងចក្រ បរិក្ខារ** សំដៅដល់គ្រឿងយន្ត ឬឧបករណ៍ផ្សេងៗសម្រាប់បម្រើឱ្យការងារគម្រោងហេដ្ឋារចនាសម្ព័ន្ធ។
- **វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់** សំដៅដល់វិញ្ញាបនបត្រសម្រាប់បញ្ជាក់នូវលក្ខណសម្បត្តិរបស់ក្រុមហ៊ុន/ សហគ្រាសក្នុងការមានសិទ្ធចូលរួមកិច្ចលទ្ធកម្មសាធារណៈចំពោះគម្រោង/ ហេដ្ឋារចនាសម្ព័ន្ធរបស់ស្ថាប័នអនុវត្តលទ្ធកម្ម/ អង្គភាពថវិកា។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## ៣. នីតិវិធីនៃការចុះបញ្ជីអ្នកទទួលការសាងសង់

អ្នកទទួលការសាងសង់ត្រូវចុះបញ្ជីចំណាត់ប្រភេទ និងចំណាត់ថ្នាក់នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ៣.១ ចំណាត់ប្រភេទនៃអ្នកទទួលការសាងសង់

អ្នកទទួលការសាងសង់ត្រូវបានបែងចែកជា ៣(បី) ប្រភេទដូចខាងក្រោម÷

- ប្រភេទតូច
- ប្រភេទមធ្យម
- ប្រភេទធំ។

### ៣.២ ចំណាត់ថ្នាក់នៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ

គម្រោងហេដ្ឋារចនាសម្ព័ន្ធត្រូវចាត់ថ្នាក់ជា ១០(ដប់) ថ្នាក់ ហើយចំណាត់ថ្នាក់នីមួយៗនៃហេដ្ឋារចនាសម្ព័ន្ធត្រូវបានកំណត់តាមប្រភេទនៃការងារសំណង់។ ឈ្មោះថ្នាក់នីមួយៗនៃហេដ្ឋារចនាសម្ព័ន្ធមានបរិយាយលម្អិតនៅក្នុងឧបសម្ព័ន្ធ១។ រាល់ការងារសាងសង់ ទោះជាសំណង់ថ្មី ការកែលម្អ ឬការស្តារឡើងវិញដែលធ្វើឡើងដោយស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាត្រូវបានធ្វើចំណាត់ថ្នាក់នៃគម្រោងដូចតទៅ÷

| លេខសម្គាល់ | ឈ្មោះថ្នាក់ |
|---|---|
| W1 | ផ្លូវថ្នល់ និងស្ពាន |
| W2 | ព្រលានយន្តហោះ |
| W3 | សំណង់អគារ និងសួនច្បារ |
| W4 | ប្រព័ន្ធធារាសាស្ត្រ |
| W5 | ផ្លូវរថភ្លើង |
| W6 | កំពង់ផែ |
| W7 | ប្រព័ន្ធទឹកស្អាត និងប្រព័ន្ធទឹកកខ្វក់ |
| W8 | សំណង់ទូរគមនាគមន៍ |
| W9 | ការតម្លើងគ្រឿងសំណង់ |
| W10 | ប្រព័ន្ធថាមពល។ |

### ៣.៣- អង្គភាពចុះបញ្ជីអ្នកទទួលការសាងសង់

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាអង្គភាពគ្រប់គ្រង និងចុះបញ្ជីអ្នកទទួលការសាងសង់។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈមានភារកិច្ចពាក់ព័ន្ធនឹងការចុះបញ្ជីអ្នកទទួលការសាងសង់ដូចខាងក្រោម÷

- ពិនិត្យ និងវាយតម្លៃលើសំណើសុំចុះបញ្ជីរបស់អ្នកទទួលការសាងសង់
- ពិនិត្យ និងវាយតម្លៃលើសំណើសុំតម្លើងប្រភេទ និងបន្ថែមចំណាត់ថ្នាក់របស់អ្នកទទួលការសាងសង់
- ចុះពិនិត្យផ្ទៀងផ្ទាត់នូវព័ត៌មានដែលមានភ្ជាប់ក្នុងសំណុំឯកសារនៃសំណើសុំចុះបញ្ជី តម្លើងប្រភេទ និងបន្ថែមចំណាត់ថ្នាក់របស់អ្នកទទួលការសាងសង់
- បដិសេធសំណើសុំចុះបញ្ជី តម្លើងប្រភេទ និងបន្ថែមចំណាត់ថ្នាក់របស់អ្នកទទួលការសាងសង់ ដែលមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់។

### ៣.៤-រយៈពេលនៃការពិនិត្យសម្រេចលើសំណើសុំចុះបញ្ជីអ្នកទទួលការសាងសង់

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈត្រូវពិនិត្យ និងវាយតម្លៃសំណុំឯកសារនៃសំណើសុំចុះបញ្ជីអ្នកទទួលការសាងសង់ឱ្យបានត្រឹមត្រូវ មុននឹងសម្រេចផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់។ ការពិនិត្យសម្រេចលើសំណើសុំចុះបញ្ជីអ្នកទទួលការសាងសង់ត្រូវធ្វើឡើង ក្នុងរយៈពេលយ៉ាងយូរ ២១ (ម្ភៃមួយ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំចុះបញ្ជី។ ក្នុងករណីពិនិត្យឃើញថាមានការខ្វះចន្លោះ ឬមានភាពមិនច្បាស់លាស់នៃសំណុំឯកសារពាក់ព័ន្ធដែលផ្តល់ដោយអ្នកស្នើសុំចុះបញ្ជី អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំចុះបញ្ជីឱ្យផ្តល់ឯកសារ ឬធ្វើការបំភ្លឺបន្ថែមក្នុងរយៈពេលមិនលើសពី ៣ (បី)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំចុះបញ្ជី។ អ្នកស្នើសុំចុះបញ្ជីត្រូវផ្តល់ឯកសារបន្ថែម ឬបំភ្លឺជាលាយលក្ខណ៍អក្សរក្នុងរយៈពេលមិនលើសពី ៣ (បី)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃអ្នកស្នើសុំចុះបញ្ជីទទួលបានសេចក្តីជូនដំណឹង។

ករណីដែលអ្នកស្នើសុំចុះបញ្ជីមិនបានផ្តល់ឯកសារបន្ថែម ឬធ្វើការបំភ្លឺជាលាយលក្ខណ៍អក្សរក្នុងរយៈពេលដូចបានកំណត់ខាងលើ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈត្រូវបដិសេធសំណើសុំចុះបញ្ជីអ្នកទទួលការសាងសង់ ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំចុះបញ្ជី។

### ៣.៥-សុពលភាពនៃវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់

អ្នកទទួលការសាងសង់ដែលបានចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងត្រូវបានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់ ដែលមានសុពលភាពរយៈពេល ៣ (បី)ឆ្នាំ។

ក្នុងរយៈពេលសុពលភាពនៃវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់ អ្នកទទួលការសាងសង់អាចដាក់ពាក្យស្នើសុំតម្លើងចំណាត់ប្រភេទ និង/ឬ បន្ថែមចំណាត់ថ្នាក់ដទៃទៀតបាន។ រាល់ការស្នើសុំតម្លើងចំណាត់ប្រភេទ និងបន្ថែមចំណាត់ថ្នាក់អ្នកទទួលការសាងសង់ត្រូវបំពេញទៅតាមលក្ខខណ្ឌតម្រូវ និងត្រូវបង់ថ្លៃសេវាទៅតាមការកំណត់។

## ៤. លក្ខខណ្ឌសម្រាប់ការចុះបញ្ជី

### ៤.១-លក្ខខណ្ឌសម្រាប់ការចុះបញ្ជីលើកដំបូង

ការចុះបញ្ជីអ្នកទទួលការសាងសង់ត្រូវផ្អែកលើលក្ខខណ្ឌសំខាន់ៗចំនួន ៤ (បួន) ដែលបញ្ជាក់អំពីលក្ខណសម្បត្តិរបស់អ្នកទទួលការសាងសង់ដែលស្នើសុំចុះបញ្ជីដូចខាងក្រោម÷

#### ក. បទពិសោធន៍ការងារ

អ្នកទទួលការសាងសង់ដែលស្នើសុំចុះបញ្ជីត្រូវបង្ហាញពីបទពិសោធន៍នៃការអនុវត្តកិច្ចសន្យាដោយជោគជ័យក្នុងរយៈពេល៣ (បី) ឆ្នាំចុងក្រោយ នូវការងារដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងចំណាត់ប្រភេទនិងចំណាត់ថ្នាក់ដែលខ្លួនបានស្នើសុំចុះបញ្ជី។ តម្លៃកិច្ចសន្យាក្នុងរយៈពេល៣ (បី) ឆ្នាំចុងក្រោយនេះ ត្រូវមានទឹកប្រាក់សរុបតាមចំណាត់ប្រភេទនីមួយៗដូចខាងក្រោម÷

- ប្រភេទតូច យ៉ាងតិច ១៥០ លានរៀល
- ប្រភេទមធ្យម យ៉ាងតិច ១.៥០០ លានរៀល
- ប្រភេទធំ យ៉ាងតិច ៥.០០០ លានរៀល។

ក្នុងករណីមិនអាចបំពេញតាមលក្ខខណ្ឌខាងលើ អ្នកទទួលការសាងសង់ដែលស្នើសុំចុះបញ្ជីអាចបង្ហាញពីបទពិសោធន៍នៃការអនុវត្តកិច្ចសន្យាដោយជោគជ័យក្នុងរយៈពេល៣ (បី) ឆ្នាំចុងក្រោយ នូវការងារដែលមានលក្ខណៈប្រហាក់ប្រហែលនឹងចំណាត់ប្រភេទនិងចំណាត់ថ្នាក់ដែលខ្លួនបានស្នើសុំ យ៉ាងហោចណាស់ចំនួនមួយគម្រោងដែលមានតម្លៃកិច្ចសន្យាតាមចំណាត់ប្រភេទនីមួយៗដូចខាងក្រោម÷

- ប្រភេទតូច យ៉ាងតិច ៧៥ លានរៀល
- ប្រភេទមធ្យម យ៉ាងតិច ៧៥០ លានរៀល
- ប្រភេទធំ យ៉ាងតិច ២.៥០០ លានរៀល។

**ខ. សមត្ថភាពបច្ចេកទេស**

**-ធនធានមនុស្ស**

អ្នកទទួលការសាងសង់ដែលស្នើសុំចុះបញ្ជី ត្រូវមានទីតាំង/ស្នាក់ការក្រុមហ៊ុន/សហគ្រាសច្បាស់លាស់ និងមានបុគ្គលិកចាំបាច់សំខាន់ៗដែលមានជំនាញបច្ចេកទេស ឬជំនាញបច្ចេកទេសសមស្របទៅនឹងចំណាត់ថ្នាក់ដែលខ្លួនបានស្នើសុំ។ អ្នកទទួលការសាងសង់ដែលស្នើសុំចុះបញ្ជីត្រូវភ្ជាប់មកជាមួយនូវបញ្ជីរាយនាមបុគ្គលិកដោយបញ្ជាក់ពីជំនាញ និងរយៈពេលនៃបទពិសោធន៍ការងាររបស់បុគ្គលិកនីមួយៗឱ្យបានច្បាស់លាស់ (ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ២)។ បញ្ជីរាយនាមបុគ្គលិកនោះត្រូវមានចុះហត្ថលេខាដោយប្រធានឬតំណាងក្រុមហ៊ុន/សហគ្រាសនិងត្រូវបោះត្រារបស់ក្រុមហ៊ុន/សហគ្រាស។

ចំពោះបុគ្គលិកជំនាញដែលជាវិស្វករ ត្រូវមានភ្ជាប់មកជាមួយនូវសញ្ញាបត្រដែលមានការបញ្ជាក់ត្រឹមត្រូវពីស្ថាប័នមានសមត្ថកិច្ចយ៉ាងយូរបំផុត ២ (ពីរ) ឆ្នាំ មុនកាលបរិច្ឆេទស្នើសុំចុះបញ្ជីនិងត្រូវមានកិច្ចសន្យាការងារជាមួយក្រុមហ៊ុន/សហគ្រាសដែលស្នើសុំចុះបញ្ជីនោះ។ វិស្វករម្នាក់ៗត្រូវមានការទទួលស្គាល់ពីគណៈវិស្វករកម្ពុជា និងមានសិទ្ធិឈរឈ្មោះបានតែមួយក្រុមហ៊ុន/សហគ្រាសប៉ុណ្ណោះសម្រាប់ការស្នើសុំចុះបញ្ជី។

ចំនួនវិស្វករ និងអ្នកបច្ចេកទេសមធ្យមតាមចំណាត់ប្រភេទនីមួយៗត្រូវបានកំណត់ដូចខាងក្រោម÷

| ប្រភេទ | ចំនួនវិស្វករ (នាក់) | ចំនួនអ្នកបច្ចេកទេសមធ្យម (នាក់) | បទពិសោធន៍ (ឆ្នាំ) |
|---|---|---|---|
| តូច | ១ | ២ | ៣ |
| មធ្យម | ២ | ៣ | ៤ |
| ធំ | ៣ | ៤ | ៥ |

**-ធនធានគ្រឿងចក្រនិងបរិក្ខារ**

អ្នកទទួលការសាងសង់ដែលស្នើសុំចុះបញ្ជី ត្រូវមានគ្រឿងចក្រនិងបរិក្ខារចាំបាច់មួយចំនួនដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនសម្រាប់អនុវត្តការងារសំណង់ទៅតាមប្រភេទនិងចំណាត់ថ្នាក់នីមួយៗក្នុងកម្រិតអប្បបរមា ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ៣។

**គ- សមត្ថភាពហិរញ្ញវត្ថុ**

អ្នកទទួលការសាងសង់ដែលស្នើសុំចុះបញ្ជីត្រូវ÷

- មានធនធានគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុ សម្រាប់អនុវត្តកិច្ចសន្យាតាមចំណាត់ប្រភេទដែលបានស្នើសុំ
- បង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ (N-1) ដែលទទួលស្គាល់ដោយអគ្គនាយកដ្ឋានពន្ធដារ
- បង្ហាញលិខិតបញ្ជាក់សាច់ប្រាក់អប្បបរមាពីធនាគារពាណិជ្ជ ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សាច់ប្រាក់អប្បបរមាសម្រាប់ការស្នើសុំចុះបញ្ជីអ្នកទទួលការសាងសង់ ត្រូវបានកំណត់តាមចំណាត់ប្រភេទនីមួយៗដូចខាងក្រោម÷

- ប្រភេទតូច យ៉ាងតិច ៣៧,៥ លានរៀល
- ប្រភេទមធ្យម យ៉ាងតិច ៣៧៥ លានរៀល
- ប្រភេទធំ យ៉ាងតិច ១.២៥០ លានរៀល។

**ឃ-ឯកសារគតិយុត្តពាក់ព័ន្ធ**

អ្នកទទួលការសាងសង់ដែលស្នើសុំចុះបញ្ជីត្រូវភ្ជាប់មកជាមួយនូវឯកសារគតិយុត្តពាក់ព័ន្ធដូចខាងក្រោម÷

- ពាក្យសុំចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការសាងសង់ (ច្បាប់ដើម) ចំនួន ១ច្បាប់
- លិខិតបញ្ជាក់សាច់ប្រាក់ចេញដោយធនាគារពាណិជ្ជ (ច្បាប់ដើម) ចំនួន ១ច្បាប់
- អាជ្ញាប័ណ្ណ/ វិញ្ញាបនបត្រប្រកបអាជីវកម្មចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង/ ឬ ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធដទៃទៀត (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ១ច្បាប់
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចេញដោយក្រសួងពាណិជ្ជកម្ម (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ១ច្បាប់
- ប័ណ្ណប៉ាតង់ឆ្នាំ N (សេវាសាងសង់) (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ១ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម (VAT) (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ១ច្បាប់
- បញ្ជីរាយនាមបុគ្គលិកក្រុមហ៊ុន/ សហគ្រាស (ច្បាប់ដើម) ចំនួន ១ច្បាប់
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ប្រធានក្រុមហ៊ុន/ សហគ្រាស (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ១ច្បាប់
- សញ្ញាបត្រវិស្វករ និងកិច្ចសន្យាការងាររបស់វិស្វករ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ១ច្បាប់
- បញ្ជីនិងរូបភាពគ្រឿងចក្រ (ច្បាប់ដើម) ចំនួន ១ច្បាប់
- បទពិសោធន៍ការងាររយៈពេល ៣ឆ្នាំចុងក្រោយ (រូបភាពនិងកិច្ចសន្យា) (ថតចម្លង) ចំនួន ១ច្បាប់
- រូបភាពទីតាំងរបស់ក្រុមហ៊ុន/ សហគ្រាស (ច្បាប់ដើម) ចំនួន ១ច្បាប់
- របាយការណ៍ហិរញ្ញវត្ថុនៃឆ្នាំ (N-1) (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ១ច្បាប់
- លក្ខន្តិកៈក្រុមហ៊ុន/ សហគ្រាស (ចម្លងត្រឹមត្រូវតាមច្បាប់ដើម) ចំនួន ១ច្បាប់។

**៤.២- លក្ខខណ្ឌសម្រាប់ការចុះបញ្ជីបន្ត**

អ្នកទទួលការសាងសង់ដែលមានបំណងចុះបញ្ជីបន្ត ត្រូវដាក់ពាក្យសុំចុះបញ្ជីក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃសម្រាប់ប្រភេទធំ និង ៣០ (សាមសិប) ថ្ងៃសម្រាប់ប្រភេទតូច ឬមធ្យម មុនវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់ (ចាស់) អស់សុពលភាព។ លក្ខខណ្ឌសម្រាប់ការចុះបញ្ជីបន្តដូចគ្នានឹងការស្នើសុំចុះបញ្ជីលើកដំបូងដែរ។

**៤.៣- លក្ខខណ្ឌសម្រាប់តម្លើងចំណាត់ប្រភេទ និងបន្ថែមចំណាត់ថ្នាក់**

ក្នុងរយៈពេលសុពលភាពនៃវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់ អ្នកទទួលការអាចដាក់ពាក្យស្នើសុំតម្លើងចំណាត់ប្រភេទ និង/ ឬ បន្ថែមចំណាត់ថ្នាក់អ្នកទទួលការសាងសង់។

**៤.៣.១- ការតម្លើងចំណាត់ប្រភេទ**

ករណីសុំតម្លើងចំណាត់ប្រភេទ អ្នកទទួលការត្រូវបំពេញលក្ខខណ្ឌបន្ថែមដូចជា បទពិសោធន៍ការងារ សមត្ថភាពបច្ចេកទេស និងសមត្ថភាពហិរញ្ញវត្ថុ ស្របតាមចំណាត់ប្រភេទដែលបានស្នើសុំ។ រីឯ សុពលភាពនៃវិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលការសាងសង់ត្រូវរក្សានៅដដែល។

៤.៣.២-ការបន្ថែមចំណាត់ថ្នាក់

ករណីសុំបន្ថែមចំណាត់ថ្នាក់ អ្នកទទួលការត្រូវបំពេញលក្ខខណ្ឌបន្ថែម ដូចជាបទពិសោធន៍ការងារ និងសមត្ថភាពបច្ចេកទេស ដែលត្រូវនឹងចំណាត់ថ្នាក់នីមួយៗដែលស្នើសុំបន្ថែម។ រីឯ សុពលភាពនៃវិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលការសាងសង់ត្រូវរក្សានៅដដែល។

**៤.៤-លក្ខខណ្ឌសម្រាប់សុំវិញ្ញាបនបត្រថ្មីជំនួសវិញ្ញាបនបត្រចាស់ដែលបាត់**

ក្នុងករណីមានការបាត់បង់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់ ដោយប្រការណាមួយ អ្នកទទួលការសាងសង់អាចស្នើសុំធ្វើវិញ្ញាបនបត្រថ្មី ដើម្បីជំនួសវិញ្ញាបនបត្រដែលបានបាត់ ដោយភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ច។ រីឯសុពលភាពនៃវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់ត្រូវរក្សានៅដដែល។

## ៥. តម្លៃសេវាចុះបញ្ជីអ្នកទទួលការសាងសង់

អ្នកទទួលការសាងសង់ដែលស្នើសុំចុះបញ្ជីត្រូវបង់ថ្លៃសេវាសម្រាប់ការចុះបញ្ជីលើកដំបូង ការចុះបញ្ជីបន្ត ការតម្លើងចំណាត់ប្រភេទ ការបន្ថែមចំណាត់ថ្នាក់ និង/ឬ ការសុំវិញ្ញាបនបត្រថ្មីជំនួសវិញ្ញាបនបត្រចាស់ដែលបាត់នៅពេលដែលអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈទទួលពាក្យស្នើសុំចុះបញ្ជីរបស់អ្នកទទួលការសាងសង់។ ថ្លៃសេវាត្រូវទូទាត់ជាប្រាក់រៀលដោយបង់ចូលក្នុងគណនីទោលរតនាគារជាតិ។ អ្នកទទួលការសាងសង់ត្រូវប្រគល់ប័ណ្ណបង់ប្រាក់ច្បាប់ដើមជូនអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ថ្លៃសេវាដែលបានបង់រួចមិនអាចបង្វិលជូនវិញឡើយ។

**តារាងតម្លៃសេវាចុះបញ្ជីអ្នកទទួលការសាងសង់**

(ឯកតាគិតជារៀល)

| ប្រភេទ | ថ្លៃសេវាចុះបញ្ជីលើកដំបូង | ថ្លៃសេវាចុះបញ្ជីបន្ត | ថ្លៃសេវាតម្លើងចំណាត់ប្រភេទ | ថ្លៃសេវាបន្ថែមចំណាត់ថ្នាក់ (សម្រាប់១ចំណាត់ថ្នាក់) | ថ្លៃសេវាសុំវិញ្ញាបនបត្រថ្មីជំនួសវិញ្ញាបនបត្រចាស់ដែលបាត់ |
|---|---|---|---|---|---|
| តូច | ៥០០.០០០ | ៤០០.០០០ | | ២០០.០០០ | ២៥០.០០០ |
| មធ្យម | ១.០០០.០០០ | ៨០០.០០០ | ៧០០.០០០ | ៤០០.០០០ | ៥០០.០០០ |
| ធំ | ២.០០០.០០០ | ១.៦០០.០០០ | ១.៤០០.០០០ | ៨០០.០០០ | ១.០០០.០០០ |

## ៦.ការផ្តល់ព័ត៌មាននិងចំណាយផ្សេងទៀតរបស់អ្នកស្នើសុំចុះបញ្ជីអ្នកទទួលការសាងសង់

អ្នកទទួលការសាងសង់ដែលបានចុះបញ្ជីរួចហើយ ចាំបាច់ត្រូវផ្តល់ព័ត៌មានដល់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈក្នុងករណីមានការផ្លាស់ប្តូរអាសយដ្ឋាន ការកែប្រែស្ថានភាពគ្រប់គ្រង ឬការប្រែប្រួលផ្សេងទៀត។

ក្នុងអំឡុងពេលនៃការពិនិត្យសំណុំឯកសារនៃសំណើសុំចុះបញ្ជីរបស់អ្នកទទួលការសាងសង់ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈអាចសាកសួរព័ត៌មានពាក់ព័ន្ធពីធនាគារ អតិថិជន ឬអ្នកឯកទេសដែលធ្លាប់បានគ្រប់គ្រងការងាររបស់អ្នកដាក់ពាក្យសុំ និងអាចសាកសួររាល់ព័ត៌មានបន្ថែមទៀតដែលយល់ថាជាការចាំបាច់។ ប្រសិនបើធនាគារ ឬអតិថិជនរបស់អ្នកដាក់ពាក្យសុំយកថ្លៃសេវាចំពោះការសាកសួរព័ត៌មាននោះ អ្នកដាក់ពាក្យសុំត្រូវតែទទួលរ៉ាប់រងរាល់សោហ៊ុយចំណាយលើសេវានោះ។

**៧- សិទ្ធិចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណ:**

អ្នកទទួលការសាងសង់ដែលបានចុះបញ្ជីរួចហើយ អាចមានសិទ្ធិចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈតាមតម្លៃគម្រោង ដូចមានកំណត់ក្នុងតារាងខាងក្រោម÷

| ចំណាត់ប្រភេទ | តម្លៃគម្រោង |
|---|---|
| - ប្រភេទតូច | តិចជាង ៥០០លានរៀល |
| - ប្រភេទមធ្យម | មិនលើសពី ៣.០០០លានរៀល |
| - ប្រភេទធំ | មិនកំណត់ |

វិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលការសាងសង់ គឺជាកម្មសិទ្ធិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅពេលដែលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់អស់សុពលភាព អ្នកទទួលការសាងសង់ត្រូវប្រគល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងករណីវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីអ្នកទទួលការសាងសង់ត្រូវបាត់បង់ដោយប្រការណាមួយ ក្រុមហ៊ុន/សហគ្រាសត្រូវបញ្ជាក់មូលហេតុច្បាស់លាស់ជាលាយលក្ខណ៍អក្សរមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានសហគ្រាសសាធារណៈ ប្រធានគ្រឹះស្ថានសាធារណៈរដ្ឋបាល ប្រធានអង្គភាពថវិកា និងប្រធានអង្គភាពចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃអង្គារ ៩រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១
ត្រូវនឹងថ្ងៃទី ១២ ខែ ធ្នូ គ.ស. ២០១៧

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ ១

## ចំណាត់ថ្នាក់សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ

| លេខសម្គាល់ | ឈ្មោះថ្នាក់ | បរិយាយ |
|---|---|---|
| W1 | ផ្លូវថ្នល់ និងស្ពាន | - ការសាងសង់ផ្លូវ(បេតុង ដីស ខ្សាច់ភ្នំ ដីក្រួសក្រហម DBST SBST AC)<br>- ស្ពាន (ប៉េតុង ដែក ឈើ)<br>- គំនូស បង្គោល និងស្លាកសញ្ញាចរាចរណ៍<br>- លូទឹក ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង ផ្លូវសម្រាប់ដើរឆ្លងកាត់<br>- របាំងទ្រូងផ្លូវ<br>- ការស្តារឡើងវិញ ការជួសជុល និងកែលម្អផ្លូវថ្នល់ ស្ពាន ប្រព័ន្ធបង្ហូរទឹក ។ |
| W2 | ព្រលានយន្តហោះ | - ការសាងសង់ផ្លូវរត់យន្តហោះ<br>- ក្រាលផ្លូវទីសំចតយន្តហោះ<br>- ការសាងសង់ប្រព័ន្ធបង្ហូរទឹកក្នុងព្រលាន<br>- ការសាងសង់រោងយន្តហោះ និងឃ្លាំងស្តុកទំនិញក្នុងព្រលាន។ |
| W3 | សំណង់អគារ និងសួនច្បារ | - ការសាងសង់អគារគ្រប់ប្រភេទ<br>- ការជួសជុលសំណង់អគារគ្រប់ប្រភេទ<br>- ការសាងសង់របងគ្រប់ប្រភេទ<br>- ការលាបពណ៌គ្រប់ប្រភេទ<br>- ការរៀបចំសួនច្បារ<br>- ការចាក់ដីបំពេញ។ |
| W4 | ប្រព័ន្ធធារាសាស្ត្រ | - ការសាងសង់និងស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រព និងប្រព័ន្ធបង្ហូរទឹក<br>- ការសាងសង់ទ្វារទឹក<br>- ការសាងសង់បណ្តាញផ្លូវក្នុងប្រព័ន្ធស្រោចស្រព<br>- ការជីកស្រះ<br>- ការរានដីក្នុងប្រព័ន្ធធារាសាស្ត្រ។ |
| W5 | ផ្លូវរថភ្លើង | - ការសាងសង់ផ្លូវដែក ស្ពានរថភ្លើង និងលូទឹកកាត់ក្រោមផ្លូវដែក<br>- ការពង្រឹង និងការជួសជុលផ្លូវដែកនិងស្ពានរថភ្លើង។ |
| W6 | កំពង់ផែ | - ការសាងសង់ប្រព័ន្ធសំណង់នៅជាប់ និងលើសមុទ្រ ឬទន្លេ ដូចជា សំណង់របាំងផែ ផែ របងផែ ចាក់គ្រឹះផែ ពោងផែឃ្លាំងផ្ទុកទំនិញ<br>- ការស្តារនិងរៀបចំ ចំណតសាឡាង<br>- ការបូមដីរៀបចំកំពង់ផែ។ |

| | | |
|---|---|---|
| W7 | ប្រព័ន្ធទឹកស្អាត និងប្រព័ន្ធទឹកកខ្វក់ | - ការសាងសង់អាងចម្រោះទឹក អាងស្តុកទឹក និងឃ្លាំងទឹក<br>- ការដាក់ប្រព័ន្ធ បំពង់ទឹក ស្ថានីយ៍បូមទឹក ប្រឡាយទឹក ទំនប់ទឹក<br>- ការអភិវឌ្ឍន៍វិស័យទឹកក្រោមដី ជីក និងសង់អណ្តូង ស្រះ និងស្ថានីយ៍បូមទឹក<br>- ការសង់ប្រព័ន្ធសំណង់លូសម្រាប់ទឹកស្អុយ និងច្រកចូលទៅបំពង់លូទឹកស្អុយ<br>- ការផ្លាស់ជំនួស ឬកែលម្អសំណង់សម្រាប់ទឹកកខ្វក់ និងបំពង់លូ ដែលខូចខាតឬមិនដំណើរការ<br>- ការជួសជុលអាងស្តុកទឹក និងឃ្លាំងទឹក<br>- ការផ្គត់ផ្គង់ និងតម្លើងបរិក្ខារ ដូចជា ម៉ាស៊ីនបូមទឹកម៉ូទ័រ និងប្រដាប់បញ្ជាចរន្តមិនត្រូវបានរាប់បញ្ចូលឡើយ។ |
| W8 | សំណង់ទូរគមនាគមន៍ | - ការដាក់បំពង់ខ្សែ និងការសាងសង់ប្រអប់រួម<br>- ការដាក់បំពង់បណ្តាញខ្សែទូរស័ព្ទ<br>- ការតម្លើងឧបករណ៍បរិក្ខារទូរគមនាគមន៍<br>- ការដាក់ប្រព័ន្ធខ្សែកាប្លិ៍ក្រោមដី និងក្រោមទឹក។ |
| W9 | ការតម្លើងគ្រឹះសំណង់ | - ការបុក ការសង្កត់ ការខួង និងការចាក់គ្រឹះសំណង់គ្រប់ប្រភេទ។ |
| W10 | ប្រព័ន្ធថាមពល | - ការសាងសង់រោងចក្រផលិតអគ្គិសនី<br>- ការសាងសង់ទំនប់វារីអគ្គិសនី<br>- ការតម្លើងប្រព័ន្ធបណ្តាញចរន្តអគ្គិសនី<br>- ការសាងសង់កាបីនភ្លើង<br>- ការសាងសង់ស្ថានីយ៍បម្លែងចរន្តអគ្គិសនី។ |

**ឧបសម្ព័ន្ធ ២**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

**ពាក្យស្នើសុំចុះបញ្ជីអ្នកទទួលការសាងសង់**

**១.ឈ្មោះក្រុមហ៊ុន/ សហគ្រាសៈ.......................................................................**

.............................................................................................................

**អាសយដ្ឋានៈ..........................................................................................**

.............................................................................................................

**លេខទូរស័ព្ទ ..............................................................................................**

**លេខទូរសារ :.............................................................................................**

**២. កម្មវត្ថុនៃការស្នើសុំ**

□ ការចុះបញ្ជីលើកដំបូង
□ ការចុះបញ្ជីបន្ត
□ ការតម្លើងចំណាត់ប្រភេទ
□ ការបន្ថែមចំណាត់ថ្នាក់
□ ការស្នើសុំវិញ្ញាបនបត្រថ្មីជំនួសវិញ្ញាបនបត្រចាស់ដែលបាត់

**៣. ចំណាត់ថ្នាក់នៃការស្នើសុំ**

(ជ្រើសយកប្រអប់ដែលដាក់ពាក្យសុំចំណាត់ថ្នាក់)

□ W1 ផ្លូវថ្នល់ និង ស្ពាន
□ W2 ព្រលានយន្តហោះ
□ W3 សំណង់អគារ និងសួនច្បារ
□ W4 ប្រព័ន្ធធារាសាស្ត្រ
□ W5 ផ្លូវរថភ្លើង
□ W6 កំពង់ផែ
□ W7 ប្រព័ន្ធទឹកស្អាត និងប្រព័ន្ធទឹកកខ្វក់
□ W8 សំណង់ទូរគមនាគមន៍
□ W9 ការតម្លើងគ្រឿងសំណង់
□ W10 ប្រព័ន្ធថាមពល

**៤. ព័ត៌មានស្តីពីស្ថានភាពហិរញ្ញវត្ថុ**

| | |
|---|---|
| ទុនជាផ្លូវការ | :....................................................រៀល |
| ទុនដែលបានបង់ | :....................................................រៀល |

ប្រកាសស្ថានភាពហិរញ្ញវត្ថុក្នុងរយៈពេល ០៣ឆ្នាំចុងក្រោយ

| ល.រ | បរិយាយ | ឯកតាគិតជារៀល | | |
|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ |
| ១ | ទ្រព្យសកម្មចល័ត | | | |
| ២ | ទ្រព្យសរុប | | | |
| ៣ | បំណុល (រយៈពេលខ្លី) | | | |
| ៤ | បំណុលសរុប | | | |
| ៥ | ទ្រព្យក្រោយកាត់បំណុល (២-៤) | | | |
| ៦ | ទុនសម្រាប់ដំណើការ (១-៣) | | | |

**ការសម្រួលដល់កិច្ចការធនាគារ :**

ឈ្មោះធនាគារ :.......................................................................................

អាសយដ្ឋានធនាគារ :.......................................................................................

លេខទូរស័ព្ទ :.......................................................................................

លេខគណនីនៅធនាគារ :.......................................................................................

**៥. ព័ត៌មានស្ដីពីធនធានមនុស្ស**

សូមភ្ជាប់ជាមួយនូវបញ្ជីរាយនាមបុគ្គលិក ដោយបញ្ជាក់អំពីតួនាទីនិងជំនាញរបស់បុគ្គលិកម្នាក់ៗឱ្យបានច្បាស់លាស់ដូចមានកំណត់ក្នុងតារាងខាងក្រោម÷

**បញ្ជីរាយនាមបុគ្គលិកក្រុមហ៊ុន** ....................................

អាសយដ្ឋាន.......................................................................................

| ល.រ | នាម និង គោត្តនាម | ភេទ | តួនាទី/មុខជំនាញ | ផ្សេងៗ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

| | | | | |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

រាជធានីភ្នំពេញ, ថ្ងៃ...............ខែ.........ឆ្នាំ.......  ព.ស.........

ត្រូវនឹងថ្ងៃទី.......ខែ...........គ.ស............

**ហត្ថលេខា និងត្រា**

**ប្រធានក្រុមហ៊ុន**

## ៦. ព័ត៌មានស្ដីពីគ្រឿងចក្រ និងបរិក្ខារ

បញ្ជីឈ្មោះគ្រឿងចក្រ និងបរិក្ខារដែលជាកម្មសិទ្ធិផ្ទាល់របស់ក្រុមហ៊ុន/ សហគ្រាស

| ល.រ | គ្រឿងចក្រនិងបរិក្ខារ | ទំហំនិងអានុភាព | ឆ្នាំផលិត | គុណភាព (មធ្យម ល្អបង្គួរ ល្អ) | ចំនួនសរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

## ៧. ព័ត៌មានស្តីពីបទពិសោធន៍ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ

❋ ព័ត៌មានស្តីពីការងារសំណង់ដែលបានអនុវត្តបញ្ចប់ដោយជោគជ័យក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ (ដោយភ្ជាប់មកជាមួយនូវកិច្ចសន្យាថតចម្លង) តាមគំរូតារាងដូចខាងក្រោម:

| បរិយាយគម្រោង | អតិថិជន/ អ្នកម្ចាស់ការ | តម្លៃកិច្ចសន្យា (រៀល) | ពេលចាប់ផ្តើម | កាលបរិច្ឆេទបញ្ចប់ជាក់ស្តែង | ការរកស៊ីរួម (%នៃការចូលហ៊ុន) | តម្លៃនៃការចូលហ៊ុន (រៀល) | មានឬគ្មានវិវាទ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| សរុប | | | | | | | |

<u>កំណត់សម្គាល់</u>÷

១. ប្រសិនបើការរកស៊ីចូលគ្នា នោះតម្លៃកិច្ចសន្យាត្រូវតែជាតម្លៃសរុបនៃកិច្ចសន្យា ។

២. ប្រសិនបើជាការទទួលបន្តក្នុងការសាងសង់នោះតម្លៃកិច្ចសន្យាត្រូវតែជាតម្លៃនៃកិច្ចសន្យាបន្ត ហើយកាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់គឺយកតាមកិច្ចសន្យាបន្តនេះ។

៣. រាល់គម្រោងបានបញ្ចប់ត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរ ដោយអ្នកម្ចាស់ការដែលពាក់ព័ន្ធ (ប្រសិនបើមាន) ។

៤. ប្រសិនបើកន្លែងសរសេរមិនគ្រប់គ្រាន់សូមបញ្ជាក់សន្លឹកដោយឡែក។

ខ្ញុំបាទ/នាងខ្ញុំសូមប្រកាស និងអះអាងថា រាល់ព័ត៌មាន និងលិខិតភ្ជាប់ដែលបានផ្តល់ជូនខាងលើ គឺជាព័ត៌មានពិត និងត្រឹមត្រូវ។

រាជធានីភ្នំពេញ, ថ្ងៃ...............ខែ..........ឆ្នាំ........ ព.ស.........

ត្រូវនឹងថ្ងៃទី........ខែ............គ.ស.............

**ហត្ថលេខា និងត្រា**

**ឧបសម្ព័ន្ធ ៣**

## លក្ខខណ្ឌ នៃគ្រឿងចក្រ បរិក្ខារចាំបាច់មួយចំនួនជាអប្បបរមាសម្រាប់ការងារសាងសង់

តម្រូវការអប្បបរិមានៃប្រភេទ និងចំនួនគ្រឿងចក្រ បរិក្ខារសំខាន់ៗសម្រាប់ការងារសាងសង់ទៅតាមចំណាត់ប្រភេទនិងចំណាត់ថ្នាក់នីមួយៗត្រូវបានកំណត់ដូចខាងក្រោម÷

| ល.រ | បរិយាយ | ប្រភេទធំ | | | | | | | | | | ប្រភេទមធ្យម | | | | | | | | | | ប្រភេទតូច | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | W1 | W2 | W3 | W4 | W5 | W6 | W7 | W8 | W9 | W10 | W1 | W2 | W3 | W4 | W5 | W6 | W7 | W8 | W9 | W10 | W1 | W2 | W3 | W4 | W5 | W6 | W7 | W8 | W9 | W10 |
| 1 | អ៊ិចស្កាវ៉ាទ័រ (Excavator) | 3 | 2 | 1 | 3 | 1 | 1 | 2 | 1 | 1 | 1 | 2 | 1 | 1 | 2 | 1 | | 1 | | | 1 | 1 | | 1 | 1 | | | 1 | | | |
| 2 | ប៊ុលដូលហ្ស៊ែ (Bulldozer) | 3 | 2 | 1 | 2 | 1 | 1 | 2 | 1 | | | 2 | 1 | 1 | 2 | | | 1 | | | | 1 | | 1 | 1 | | | | | | |
| 3 | រថយន្តដឹកដី (Dump Truck) | 3 | 3 | 2 | 3 | 2 | 2 | 2 | 1 | 1 | 1 | 2 | 1 | 1 | 2 | 1 | 1 | 2 | | | | 2 | 1 | 1 | 1 | | | 1 | | | |
| 4 | រថយន្តដឹកទំនិញ (Cargo Truck) | 2 | 1 | 2 | 2 | 1 | 1 | 2 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | | | 1 | 1 | | 1 | 1 | | | 1 | | | |
| 5 | រថយន្តដឹកទឹក ឬ ស្រោចទឹក (Water Truck) | 2 | 1 | 1 | 1 | 1 | 1 | 1 | | | | 2 | 1 | 1 | 1 | | | | | | | 1 | | | 1 | | | | | | |
| 6 | រ៉ូឡូបង្ហាប់ដី (Rollo) | 2 | 2 | | 1 | | | 1 | | | | 2 | 1 | | 1 | | | | | | | 1 | 1 | | 1 | | | | | | |
| 7 | ម៉ាស៊ីនផ្លុំខ្យល់ (Air Compressor) | 3 | | | | | | | | | | 2 | | | | | | | | | | 1 | | | | | | | | | |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 8 | គ្រាក់ទ័របោសថ្នល់ (Broomer Machine) | 1 | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 9 | ម៉ាស៊ីនបង្ហាប់ដី (Tamping Rammer) | 2 | 1 | | 1 | 2 | | 1 | | | | 2 | 1 | | 1 | | | 1 | | | | 1 | 1 | | | | | | | | |
| 10 | ម៉ាស៊ីនលាយស៊ីម៉ង់ត៍ (Concrete Mixer) | 2 | 2 | 2 | 1 | | 2 | 2 | 1 | | 1 | 1 | 1 | 2 | 1 | | 1 | 1 | | | | 1 | 1 | 1 | 1 | | 1 | | | | |
| 11 | ម៉ាស៊ីនភ្លើង (Generator) | 1 | 1 | 1 | 1 | | 1 | | 1 | | 1 | 1 | 1 | | 1 | | 1 | | 1 | | | 1 | 1 | | | | | | | | |
| 12 | ម៉ាស៊ីនបូមទឹក (Water Pump) | 2 | 2 | 2 | 2 | | 1 | 3 | | | | 1 | 1 | 1 | 1 | | | 2 | | | | 1 | 1 | 1 | 1 | | | 1 | | | |
| 13 | ម៉ាស៊ីនកាត់ដែក (Rebar Cutting) | 2 | 1 | 3 | 1 | 2 | 1 | | 2 | | | 1 | 1 | 2 | 1 | 1 | | | 1 | | | 1 | 1 | 1 | | 1 | | | | | |

<u>ឧបសម្ព័ន្ធ ៤</u>

## របាយការណ៍វាយតម្លៃ
## ការចុះបញ្ជីចំណាត់ប្រភេទ និងចំណាត់ថ្នាក់
## អ្នកទទួលការសាងសង់

**១. ឈ្មោះក្រុមហ៊ុន/សហគ្រាស:**...........................................................

**២.ឈ្មោះនាយក/អ្នកគ្រប់គ្រង** :.................................................

**៣. អាសយដ្ឋាន** : ...........................................................

**លេខទូរស័ព្ទ** : ........................................................

**លេខទូរសារ** : ..........................................................

**៤.អាជ្ញាប័ណ្ណ/ វិញ្ញាបនបត្រប្រកបអាជីវកម្មចេញដោយក្រសួងពាណិជ្ជកម្ម និង/ឬក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង/ឬក្រសួង/ស្ថាប័នជំនាញពាក់ព័ន្ធដទៃទៀត :** ......................................................................

..................................................................

**៥. លក្ខណៈវិនិច្ឆ័យសម្រាប់ការចុះបញ្ជីលើចំណាត់ប្រភេទនិងចំណាត់ថ្នាក់:** ...............................................

បានពិនិត្យ និងផ្ទៀងផ្ទាត់រួច÷

ក/ បទពិសោធន៍ការងារក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ

☐ តូច ☐ មធ្យម ☐ ធំ

❖ ក្រុមហ៊ុន/សហគ្រាស............................................................

កន្លងមកបានទទួលការងារសំណង់ប្រភេទ÷ ..........................................។

ខ/សមត្ថភាពបច្ចេកទេស÷

១. ធនធានមនុស្ស

☐តូច ☐ មធ្យម ☐ ធំ

❖ ធនធានមនុស្សរបស់ក្រុមហ៊ុន/សហគ្រាស...........................មានបុគ្គលិកសរុបចំនួន ...........នាក់ ក្នុងនោះមានវិស្វករចំនួន.............នាក់ អ្នកបច្ចេកទេសជាន់ខ្ពស់ចំនួន.......... នាក់ និងមានបទពិសោធន៍ចំនួន..............ឆ្នាំ។

២. ធនធានគ្រឿងចក្រនិងបរិក្ខារ

☐តូច ☐ មធ្យម ☐ ធំ

❖ ក្រុមហ៊ុន/សហគ្រាស......................មានគ្រឿងចក្របរិក្ខារសរុបចំនួន............. ប្រភេទ ក្នុងនោះមាន..........................................................................សម្រាប់ធ្វើ ការងារសំណង់.............................។

គ/ សមត្ថភាពហិរញ្ញវត្ថុ

☐ តូច ☐ មធ្យម ☐ ធំ

❖ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ(N-1)របស់ក្រុមហ៊ុន/សហគ្រាស....................................... .............................បានទទួលស្គាល់ដោយអគ្គនាយកដ្ឋានពន្ធដារ និងសាច់ប្រាក់អប្បបរមា ក្នុងធនាគារពាណិជ្ជមានចំនួន.......................................រៀល។

**សន្និដ្ឋាន៖**

- **ការយល់ព្រមលើចំណាត់ប្រភេទ :**

☐ តូច ☐ មធ្យម ☐ ធំ

- **ការយល់ព្រមលើចំណាត់ថ្នាក់ :**

☐ W1 ផ្លូវថ្នល់ និងស្ពាន

☐ W2 ព្រលានយន្តហោះ

☐ W3 សំណង់អាគារ និងសួនច្បារ

☐ W4 ប្រព័ន្ធធារាសាស្ត្រ

☐ W5 ផ្លូវរថភ្លើង

☐ W6 កំពង់ផែ

☐ W7 ការផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធលូទឹកកខ្វក់

☐ W8 សំណង់ទូរគមនាគមន៍

☐ W9 ការតម្លើងគ្រឿងសំណង់

☐ W10 ប្រព័ន្ធថាមពល

យោងតាមការពិនិត្យ និងផ្ទៀងផ្ទាត់លើបទពិសោធន៍ការងារក្នុងរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ សមត្ថភាពបច្ចេកទេស និងសមត្ថភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន/សហគ្រាស..............................................ពិនិត្យឃើញថា ក្រុមហ៊ុន/សហគ្រាសនេះមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលការងារសំណង់ដូចខាងលើ។

រាជធានីភ្នំពេញ, ថ្ងៃ...............ខែ..........ឆ្នាំ........ ព.ស.........

ត្រូវនឹងថ្ងៃទី........ខែ............គ.ស............

**អ្នកធ្វើរបាយការណ៍**

រាជធានីភ្នំពេញ, ថ្ងៃ...............ខែ..........ឆ្នាំ........ ព.ស.........

ត្រូវនឹងថ្ងៃទី........ខែ............គ.ស............

**បានឃើញនិងឯកភាព**

**អនុប្រធាននាយកដ្ឋានទទួលបន្ទុក**

**<u>ឧបសម្ព័ន្ធ ៥</u>**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ:...................អលសា

**វិញ្ញាបនបត្រ**

**បញ្ជាក់ការចុះបញ្ជីអ្នកទទួលការសងសង់**

**នាមករណ៍** : **ក្រុមហ៊ុន/សហគ្រាស**........................................................
(សរសេរជាអក្សរឡាតាំង)........................................................

**លេខចុះបញ្ជី** : .........................អលសា ចុះថ្ងៃទី.......ខែ........ឆ្នាំ................

**ត្រូវបានទទួលស្គាល់ជា ÷**

- **ប្រភេទ** : ........................................................
- **ចំណាត់ថ្នាក់** : ........................................................

**សុពលភាព** : ពីថ្ងៃទី.......ខែ........... ឆ្នាំ......... ដល់ថ្ងៃទី ......... ខែ............ឆ្នាំ..........

អ្នកកាន់វិញ្ញាបនបត្រនេះត្រូវគោរពច្បាប់និងបទប្បញ្ញត្តិ ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

រាជធានីភ្នំពេញ, ថ្ងៃ................ខែ..........ឆ្នាំ........ ព.ស.........
ត្រូវនឹងថ្ងៃទី........ខែ...........គ.ស............

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**